**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៤៧/១៥ ក.អ.ជ.ប្រក

ថ្ងៃ ពុធ ៤កើត ខែបឋមាសាឍ ឆ្នាំមមែ ព.ស.២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា គ.ស. ២០១៥

# ប្រកាស

## ស្ដីពី

## ការបន្ថែមសមាជិកគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្ដីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្ដីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម/

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- យោងប្រកាសលេខ ១២៨/១៥ ក.អ.ជ.ប្រក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធភាពលទ្ធកម្មប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងបន្ថែមសមាជិកគណៈកម្មាធិការលទ្ធកម្ម (គល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | | |
|---|---|---|
| ១- **ឯកឧត្តម យ៉ិន សុផល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ២- **លោក ទួន តិរម្យ** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |

**ប្រការ ២.-** តែងតាំងបន្ថែមសមាជិកអង្គភាពលទ្ធកម្ម (អល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | |
|---|---|
| ១- **លោក ឌី ដារាឧុង** | សមាជិក |
| ២- **កញ្ញា ម៉ៅម សុហ្វីយ៉ា** | សមាជិក |
| ៣- **លោក អ៊ុំ ចន្ទសុវណ្ណា** | សមាជិក |
| ៤- **លោក ឃុន សុខលាង** | សមាជិក |

**ប្រការ ៣.-** គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានកំណត់ក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រកាសលេខ ៣៨១ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៤.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីជនដូចមានរាយនាមក្នុងប្រការ ២ និងប្រការ ៣ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

<u>**កន្លែងទទួល**</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ៥
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ

ជា សុផារ៉ា



Download